ដំណើរការវិវត្តរបស់កូនអ្នក

បទដ្ឋានសិក្សាស្រមាប់ឆ្នាំសិក្សា 2016–17

រដ្ឋ Washington មានបទដ្ឋានសិក្សា K-12 ដែលកំណត់ចំណេះដឹងនិងជំនាញដែលសិស្សនីមួយៗត្រូវការ ដើម្បីត្រៀមខ្លួនស្រមាប់អាជីពការងារ មហាវិទ្យាល័យ និងជីវិត នៅពេលដែលពួកគេបញ្ចប់មធ្យមសិក្សា។

ខាងក្រោមនេះ គឺជាឧទាហរណ៍សង្ខេបអំពីគោលដៅសិក្សាចំបងៗរបស់រដ្ឋ Washington ស្រមាប់ថ្នាក់ទី 1។ ស្រមាប់ព័ត៌មានពេញលេញបន្ថែម សូមចូលទៅកាន់៖

www.YourChildsProgress.com

- **សិល្បៈ។** បង្កើតការចាប់ និងការផ្តោតអារម្មណ៍; ស្រាវជ្រាវពីសទ្ទសញ្ញា និងបទភ្លេង; យល់អំពីរចនាសម្ព័ន្ធរឿង ស្រាវជ្រាវពីឧបករណ៍ និងបច្ចេកទេសសិល្បៈ។
- **បច្ចេកវិទ្យាក្នុងការអប់រំ។** ស្រាវជ្រាវគេហទំព័រនានា ដូចជា ថ្នាក់សិក្សាជាមួយនឹងរូបសត្ត្ব ម្ហូបអាហារ និងពណ៌ ដើម្បីព្រងើកការយល់ដឹងអំពីវាក្យសព្ទ។
- **សិល្បៈភាសាអង់គ្លេស (ELA)។** អាន និងយល់ពីអត្ថបទទៅតាមក្រមិតថ្នាក់ស្រមាប់ការកំសាន្ត និងជាព័ត៌មាន; សរសេរស្រមាប់គោលបំណងនិងអ្នកអានផ្សេងៗ។
- **ការអប់រំសុខភាព និងរាងកាយ។** សិក្សាអំពីការអប់រំរាងកាយ និងរចនាសម្ព័ន្ធនិងមុខងារមូលដ្ឋាននៃប្រព័ន្ធរាងកាយ បង្កើតជំនាញសង្គម កែលម្អជំនាញចលនារាងកាយ និងជំនាញធ្វើដោយៃដ។
- **គណិតវិទ្យា។** ធ្វើការជាមួយនឹងលេខទាំងមូល ហើយដាក់តែម្ត រួមមានការតំរៀបជាក្រុមដែលជាលេខដប់ និងលេខមួយ បូក និងដករហូតដល់លេខ 20។
- **វិទ្យាសាស្ត្រ។** សិក្សាអំពីសេម្លង និងពន្លឺ រុក្ខជាតិ សត្ត្ব និងវត្ថុនានានៅលើមេឃ។
- **សិក្សាសង្គម។** ស្រាវជ្រាវពីរបៀបដែលក្រុមគ្រួសាររស់នៅ និងធ្វើការរួមគ្នា ដោយប្រើបាស់គំនិតពីពលរដ្ឋវិទ្យា សេដ្ឋកិច្ចវិទ្យា ភូមិវិទ្យា និងប្រវត្តិវិទ្យា។

រដ្ឋ Washington ក៏មានបទដ្ឋានសិក្សាជា **និរន្តរភាព និងបរិស្ថានរួមបញ្ចូលគ្នា ភាសាពិភពលោក ការអប់រំការងារ និងបច្ចេកទេស** (គោលការណ៍និងបទដ្ឋានឧស្សាហកម្មស្រមាប់បឋមសិក្សា និងមធ្យមសិក្សា) **សមត្ថភាពជំនាញភាសាអង់គ្លេស** (ជា ELA គណិតវិទ្យា និងវិទ្យាសាស្ត្រ) ក៏ដូចជាគោលការណ៍ណែនាំស្រមាប់ **ការរៀនសូត្រមុនអាយុកំណត់** (ពីពេលកើត ដល់ថ្នាក់ទី 3) ដែលបំពេញបន្ថែមការអប់រំពេញលេញស្រមាប់សិស្សទាំងអស់។

ការអប់រំពិសេស៖ សិស្សដែលទទួលសេវាមានការស្នាក់នៅ ការកែស្រមួល និងការគាំទ្រដែលបានកំណត់នៅក្នុងគោម្រាងអប់រំផ្ទាល់ខ្លួនរបស់ពួកគេ។

អ្នកសិក្សាភាសាអង់គ្លេស៖ សិស្សដែលកំពុងរៀននិយាយភាសាអង់គ្លេសមានបទដ្ឋានសមត្ថភាពភាសាដែលជួយគ្រូបង្រៀនក្នុងការធ្វើផែនការណែនាំឆ្លងមុខវិជ្ជាដែលសម្រេសបទៅតាមក្រមិតនៃការអភិវឌ្ឍន៍ផ្នែកភាសារបស់សិស្សនីមួយៗ។

ថ្នាក់ 1

គោលដៅសិក្សារបស់រដ្ឋ Washington

អង្គនីតិបញ្ញត្តិរបស់រដ្ឋ Washington បានបង្កើតគោលដៅសិក្សាបួន ដើម្បីផ្តល់មូលដ្ឋានគ្រឹះស្រមាប់ការបង្កើតបទដ្ឋានសិក្សាអប់រំទាំងអស់នៅក្នុងរដ្ឋ៖

1. អានដោយការត្រិះរិះ សរសេរប្រកបដោយប្រសិទ្ធិភាព និងទំនាក់ទំនងដោយជោគជ័យ តាមរបៀប និងបរិបទផ្សេងៗនិងជាមួយអ្នកស្តាប់ផ្សេងៗទៀត។
2. ដឹង និងអនុវត្តទស្សន: និងគោលការណ៍ស្នូលនៃគណិតវិទ្យា វិទ្យាសាស្ត្រសង្គម វិទ្យាសាស្ត្ររូប និងវិទ្យាសាស្ត្រជីវ: ពលរដ្ឋវិទ្យា និងប្រវត្តិវិទ្យា រួមទាំងវប្បធម៌ផ្សេងៗ និងការចូលរួមនៅក្នុងរដ្ឋាភិបាលតំណាង ភូមិវិទ្យា សិល្បៈ និងសុខភាព និងភាពសមសួន។
3. គិតដោយវិភាគ ប្រកបដោយវិចារណញ្ញាណ និងលក្ខណៈច្នៃប្រឌិត និងដើម្បីរួមបញ្ចូលអក្សរកម្ម និងភាពចេះស្ទាត់ខាងបច្ចេកវិទ្យា ក៏ដូចជាបទពិសោធន៍ និងចំណេះដឹងផ្សេងៗគ្នា ដើម្បីបង្កើតការវិនិច្ឆ័យដែលមានហេតុផល និងដោះស្រាយបញ្ហានានា និង
4. យល់ពីសារៈសំខាន់នៃការងារនិងហិរញ្ញវត្ថុ និងពីរបៀបដែលការអនុវត្ត ការប្រឹងប្រែង និងការសម្រេចចិត្ត ជះឥទ្ធិពលដោយផ្ទាល់លើឱកាសការងារ និងការអប់រំនាពេលអនាគត។

ការិយាល័យស្នងការសចក្តីណែនាំសាធារណ
(Office of Superintendent of Public Instruction)
www.k12.wa.us

September 2016, Publication No. 16-0032

ការធ្វើតេស្តថ្នាក់រដ្ឋនៅក្នុងរដ្ឋ Washington

ច្បាប់សហព័ន្ធ ត្រូវតម្រូវឲ្យមានការធ្វើតេស្តប្រចាំឆ្នាំលើសិស្សថ្នាក់ទី 3-8 និងធ្វើតេស្តម្តងទៀតនៅមធ្យមសិក្សាលើសិល្ប:ភាសាអង់គ្លេស (ELA) និងគណិតវិទ្យា និងនៅថ្នាក់ទី 5 និងទី 8 និងម្តងទៀតនៅមធ្យមសិក្សាខាងវិទ្យាសាស្ត្រ។ រដ្ឋ Washington ក៏ត្រូវតម្រូវឲ្យសិស្សប្រឡងជាប់តេស្តជាក់លាក់មួយចំនួន ដើម្បីឲ្យអាចបញ្ចប់ការសិក្សាពីមធ្យមសិក្សាបានផងដែរ។

សិស្សភាគច្រើននៅថ្នាក់ទី 3-8 នឹងធ្វើតេស្ត **Smarter Balanced (ពុលស្ការពាកានៃ៉ាតណ្ណាសវ៉ាយ)**លើ ELA និងគណិតវិទ្យា និងការវាស់តម្លៃនការរីកចម្រើនសិស្ស **(MSP)** ខាងវិទ្យាសាស្ត្រ។ តេស្តទាំងនេះអាចត្រូវបានធ្វើឡើងដោយមាន ឬគ្មាន សម្ភារ: ការគាំទ្រ ឬការរៀបចំ។

សិស្សដែលមានបញ្ហាប្រឈមការយល់ដឹងធ្ងន់ធ្ងរដែលបានចង្រកងជាងកន្លះ នៅក្នុងកម្មវិធីអប់រំរួមជនរបស់ពួកគេ (IEP) ធ្វើការវាយតម្លៃដែលមានជម្រើសនៅក្នុង ELA គណិតវិទ្យា និងវិទ្យាសាស្ត្រដែលបានគេហៅថារដ្ឋវ៉ាស៊ីនតាន - មេធ្យាបាយទៅការនៅសចក្តីណែនាំ និងរង្វាស់ (**WA-AIM**)។

ការធ្វើតេស្តថ្នាក់រដ្ឋ *មិន*គួរជាការវិនិច្ឆ័យតែមួយគត់លើជំនាញ និងចំណេះដឹងសិក្សារបស់សិស្សឡើយ។ ប្រសិនបើអ្នកមានសំណួរអំពីការសិក្សារបស់កូនអ្នក សូមទំនាក់ទំនងសាលារៀន ឬគ្រូរបស់កូនអ្នក។

សិស្សដែលរៀននិយាយភាសាអង់គ្លេសនៅថ្នាក់ទី K–12 នឹងត្រូវធ្វើការវាយតម្លៃសមត្ថភាពភាសាអង់គ្លេសស្រមាប់សតវត្ស៍ទី 21 (**ELPA21**) ។ ការវាយតម្លៃនេះវាស់ជំនាញភាសាអង់គ្លេស និងការលូតលាស្រ់បចាំឆ្នាំចំពោះការអាន ការសរសេរ ការស្តាប់ និងការនិយាយជាភាសាអង់គ្លេស។ សិស្សដែលទទួលបានក្រមិតជំនាញ១ការលេចចេញ ឬការីកចម្រើនលើ ELPA21 ១ លក្ខណ:គ្រប់គាន់ដើម្បីទទួលបានសេវាគាំទ្រកម្មវិធីភាសាអង់គ្លេស។

សំណួរជាទូទៅស្តីពីការធ្វើតេស្តថ្នាក់រដ្ឋ

ហេតុអ្វីបានជាកូនខ្ញុំត្រូវធ្វើតេស្តថ្នាក់រដ្ឋទាំងនេះ?

ការធ្វើតេស្តថ្នាក់រដ្ឋត្រូវបានតម្រូវដោយច្បាប់រដ្ឋ និងសហព័ន្ធ។ វាមិនមានជាវិធីតែមួយក្នុងការស្វែងយល់ថាតើសិស្សម្នាក់កំពុងសិក្សាយ៉ាងដូចម្តេចនៅក្នុងសាលានោះទេ ប៉ុន្តែវាអាចជួយកំណត់ពីបញ្ហាសិក្សាបន្តិចម្តងៗ។

នៅមធ្យមសិក្សា ការប្រឡងជាប់តេស្តថ្នាក់រដ្ឋ ឬជាជម្រើសដែលបានអនុម័តបានបង្ហាញថាសិស្សមានមូលដ្ឋានគ្រឹះរឹងមាំលើជំនាញសិក្សា ដោយមិនគិតពីសាលាដែលពួកគេសិក្សា ឬកន្លែងដែលពួកគេជ្រើសរើសធ្វើក្រោយពេលបញ្ចប់ការសិក្សារួចហើយ។

តើខ្ញុំអាចមើលតេស្តរបស់កូនខ្ញុំបានទេ?

ស្រមាប់មូលហេតុសុវត្ថិភាពក្នុងការធ្វើតេស្ត សិស្សមិនអាចពិភាក្សាអំពីខ្លឹមសារនៃតេស្តថ្នាក់រដ្ឋជាមួយគ្រួសារ និងមិត្តភ័ក្តិរបស់ពួកគេឡើយ។ ទោះយ៉ាងណា ក្រុមគ្រួសារត្រូវបានស្វាគមន៍ដើម្បីពិនិត្យការធ្វើតេស្តរបស់កូនពួកគេបន្ទាប់ពីពួកគេត្រូវបានដាក់ពិន្ទុ។

ការធ្វើតេស្តជាយក្រមិតថ្នាក់ក្នុងឆ្នាំ 2016-17

	មេត្តយ្យ	ទី 1	ទី 2	ទី 3	ទី 4	ទី 5	ទី 6	ទី 7	ទី 8
ELA				✓	✓	✓	✓	✓	✓
គណិតវិទ្យា				✓	✓	✓	✓	✓	✓
វិទ្យាសាស្ត្រ						✓			✓

កំណត់ចំណាំ:

- ការការវាយតម្លៃជំនាញភាសាអង់គ្លេសគឺចាំបាច់ស្រមាប់សិស្សក្នុងការរៀននិយាយភាសាអង់គ្លេស។ សិស្សធ្វើតេស្តដើម្បីមានលក្ខណ:គ្រប់គាន់ដើម្បីទទួលការគាំទ្រ។ ពួកគេបន្តធ្វើតេស្តជារៀងរាល់ឆ្នាំ រហូតទាល់តពួកគេឈានដល់សមត្ថភាពជំនាញភាសាអង់គ្លេស។
- ការធ្វើតេស្តផ្សេងទៀតត្រូវបានទាមទារចាំបាច់ ប៉ុន្តែតាមតំបន់មានភាពបត់បែនក្នុងការជ្រើសរើសការធ្វើតេស្តមួយចំនួននិងក្នុងការសម្រេចចិត្តនៅពេលដែលសិស្សទទួលធ្វើតេស្ត។ ការធ្វើតេស្តនេះរួមបញ្ចូលទាំងការអានថ្នាក់ទីពីរនិងការធ្វើតេស្តដែលមានមូលដ្ឋាននៅក្នុងថ្នាក់រៀន សិក្សាសង្គម សិល្ប: ការអប់រំសុខភាពនិងរាងកាយនិងមុខវិជ្ជាផ្សេងទៀត។ ព័ត៌មានបន្ថែមអាចត្រូវបានរកឃើញនៅក្នុងតំបន់ប្រធានបទនៅតំណភ្ជាប់តាម http://www.k12.wa.us/assessment/default.aspx។
- សាលាតាមតំបន់ក៏អាចនឹងត្រូវតម្រូវឲ្យធ្វើតេស្តបន្ថែមដែរ។ សូមពិនិត្យតាមតំបន់មូលដ្ឋានរបស់អ្នកស្រមាប់ភាពលម្អិតបន្ថែមទៀត។

រយៈពេលការធ្វើតេស្តរដ្ឋ

ការធ្វើតេស្តត្រូវបានគ្រោងនៅក្នុងរយៈពេលដែលបានរាយខាងក្រោម។ សូមទាក់ទងមណ្ឌលសាលារៀនក្នុងតំបន់របស់អ្នក ដើម្បីដឹងពីកាលបរិច្ឆេទណាខ្លះដែលកូនរបស់អ្នក នឹងត្រូវធ្វើតេស្ត។

រយៈពេលការធ្វើតេស្តរបស់រដ្ឋ	
ថ្ងៃទី 17 ខែតុលា– ថ្ងៃទី 7 ខែឧសភា:	WA-AIM
ថ្ងៃទី 1 ខែកុម្ភៈ – ថ្ងៃទី 14 ខែមីនា *(បណ្តោះអាសន្ន)*:	ELPA21
ថ្ងៃទី 6 ខែមីនា – ថ្ងៃទី 9 ខែមិថុនា:	Smarter Balanced
ថ្ងៃទី 17 ខែឧសភា – ថ្ងៃទី 2 ខែមិថុនា:	វិទ្យាសាស្ត្រ MSP

OSPI ផ្តល់នូវតារាងការណ៍ពិន្ទុស្រមាប់ការធ្វើតេស្តរាយខាងលើទាំងអស់។ សូមទាក់ទងមកសាលាថ្នាក់តំបន់មូលដ្ឋានរបស់អ្នកស្រមាប់ព័ត៌មានបន្ថែមទៀត។

តើពិន្ទុតេស្តថ្នាក់រដ្ឋមានន័យដូចម្តេច?

ក្រមិតទី **4** — **លើសពីស្តង់ដាសមិទ្ធិផល:** បង្ហាញឱ្យឃើញពីការរីកចំរើនក្រមិតខ្ពស់ឆ្ពោះទៅរកភាពពូកែនចំណេះដឹងនិងជំនាញក្នុងមុខវិជ្ជាមួយ។

ក្រមិតទី **3** — **លំពាយស្តង់ដារសមិទ្ធិផល:** បង្ហាញឱ្យឃើញពីការរីកចម្រើនឆ្ពោះទៅរកភាពពូកែនចំណេះដឹងនិងជំនាញក្នុងមុខវិជ្ជាមួយ។

ក្រមិតទី **2** — **ជិតលំពាយតាមស្តង់ដាសមិទ្ធិផល:** អាចត្រូវឱ្យមានការអភិវឌ្ឍបន្ថែមទៀតដើម្បីបង្ហាញពីចំណេះដឹងនិងជំនាញក្នុងមុខវិជ្ជាមួយ។

ក្រមិតទី **1** — **មិនបានលំពាយតាមស្តង់ដារសមិទ្ធិផល:** ត្រូវការភាពប្រសើរឡើងចម្រើនដើម្បីបង្ហាញពីចំណេះដឹងនិងជំនាញក្នុងមុខវិជ្ជាមួយ។

Office of Superintendent of Public Instruction
Old Capitol Building
P.O. Box 47200
Olympia, WA 98504-7200

www.YourChildsProgress.com

September 2016, Publication No. 16-0032